00210160

A189/I/7

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គបុរេជំនុំជម្រះ
PRE-TRIAL CHAMBER
CHAMBRE PRELIMINAIRE

សំណុំរឿងព្រហ្មទណ្ឌ លេខ: ០០២/១៩-០៩-២០០៧-អវតក-កសចស (អបជ១០)

ចំពោះមុខ: ចៅក្រម ប្រាក់ គឹមសាន ប្រធាន
ចៅក្រម Rowan DOWNING
ចៅក្រម នៃយ ថុល
ចៅក្រម Katinka LAHUIS
ចៅក្រម ហួត វុទ្ធី

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 07 / 08 / 2008
ម៉ោង (Time/Heure): 14:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

កាលបរិច្ឆេទ: ៧ សីហា ២០០៨

## សេចក្ដីសម្រេចចំពោះការបញ្ជាក់លើបណ្ដឹងឧទ្ធរណ៍របស់លោក អៀង សារី ដែលប្ដឹងប្រឆាំងចំពោះការចាត់តាំងអ្នកជំនាញ ដោយផ្អែកលើសេចក្ដីសន្និដ្ឋានជាលាយលក្ខណ៍អក្សរតែប៉ុណ្ណោះ

**ការិយាល័យសហព្រះរាជអាជ្ញា**

ជា លាង
Robert PETIT
យ៉េត ចរិយា
William SMITH
តាន់ សេណារ៉ុង
Anees AHMED

**ជនត្រូវចោទ**

អៀង សារី

**មេធាវីដើមបណ្ដឹងរដ្ឋប្បវេណី**

ហុង គឹមសួន
ឡោ ជុនធី
នី ចាន់ឌី
គង់ ពិសី
Silke Studzinsky
យុង ផានិត

**សហមេធាវីការពារក្ដី**

អាង ឧត្ដម
Michael G. KARNAVAS

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 07 / 08 / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: UCH ARUN

អង្គបុរេជំនុំជម្រះ PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

១. **អង្គបុរេជំនុំជម្រះ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អវតក")** កត់សម្គាល់ឃើញ មាន "បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងសកម្មភាពដែលមានគោលដៅបដិសេធដោយចេតនា របស់សហចៅក្រមស៊ើប អង្កេត ទៅលើសំណើសុំអោយអ្នកជំនាញផ្នែកចិត្តសាស្ត្រពិនិត្យសុខភាពលោក អៀង សារី ដើម្បីសម្រេចពីសម្បទា ក្នុងការចូលរួមសវនាការ" ចុះថ្ងៃទី២ ខែកក្កដា ឆ្នាំ២០០៨ ("បណ្ដឹងឧទ្ធរណ៍")។

២. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញមាន សំណើរបស់ជនត្រូវចោទសុំឱ្យធ្វើការសម្រេចបណ្ដឹងឧទ្ធរណ៍ ដោយផ្អែកលើសេចក្ដីសន្និដ្ឋានជាលាយលក្ខណ៍អក្សរតែប៉ុណ្ណោះ ហើយពិចារណាឃើញថា "ដោយសារតែ លក្ខណៈបន្ទាន់នៃបណ្ដឹងឧទ្ធរណ៍នេះ សវនាការពេញអង្គមិនចាំបាច់រៀបចំឡើងឡើយ។" [១]

៣. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា សហព្រះរាជអាជ្ញាបានធ្វើសំណើដូចគ្នា ដោយធ្វើការសន្និដ្ឋានថា "ភាគីបានធ្វើសេចក្ដីសន្និដ្ឋានលើអង្គហេតុ និងអង្គច្បាប់បានពេញលេញចំពោះបណ្ដឹងឧទ្ធរណ៍នេះ។"[២]

៤. អនុលោមតាមវិធាន ៧៧(៣)នៃវិធានផ្ទៃក្នុង អង្គបុរេជំនុំជម្រះត្រូវធ្វើការកំណត់កាលបរិច្ឆេទសវនាការ បន្ទាប់ពីទទួលបានបណ្ដឹងឧទ្ធរណ៍ ឬពាក្យសុំ។[៣]

៥. បន្ទាប់ពីធ្វើការពិចារណាអំពីការយល់ឃើញរបស់ជនត្រូវចោទ និងសហព្រះរាជអាជ្ញា ("ភាគី") ដែលបាន លើកឡើងនៅក្នុងសេចក្ដីសន្និដ្ឋានរបស់ពួកគេរួចមក អង្គបុរេជំនុំជម្រះយល់ឃើញថា បណ្ដឹងឧទ្ធរណ៍នេះអាចយក មកធ្វើការសម្រេច ដោយផ្អែកលើតែសេចក្ដីសន្និដ្ឋានជាលាយលក្ខណ៍អក្សររបស់ភាគីបាន។

៦. អនុលោមតាមមាត្រា ៨(៤)នៃសេចក្ដីណែនាំអនុវត្តស្ដីពីការដាក់ឯកសារនៅ អ.វ.ត.ក សំណើឆ្លើយតបចំពោះ សារណានឹងត្រូវអនុញ្ញាត ក្នុងករណីដែលមិនមានអំណះអំណាងពេញអង្គដោយផ្ទាល់មាត់។[៤]

---

[១] បណ្ដឹងឧទ្ធរណ៍ប្រឆាំងចំពោះការបដិសេធតាមការសន្មតរបស់សហចៅក្រមស៊ើបអង្កេតលើសំណើសុំឱ្យអ្នកជំនាញផ្នែកចិត្តវេជ្ជវិជ្ជាធ្វើការពិនិត្យលោក អៀង សារី ដើម្បី បញ្ជាក់អំពីសម្បទារបស់គាត់ក្នុងការជំនុំជម្រះ ចុះថ្ងៃទី២ ខែកក្កដា ឆ្នាំ២០០៨ A189/I/1 វាក្យខណ្ឌទី ៥ ទំព័រទី ៦។

[២] សេចក្ដីសន្និដ្ឋានតបរបស់សហព្រះរាជអាជ្ញាចំពោះបណ្ដឹងឧទ្ធរណ៍របស់លោក អៀង សារី ស្ដីពីការចាត់តាំងអ្នកជំនាញដើម្បីវាយតម្លៃសម្បទារបស់គាត់ក្នុងការជំនុំជម្រះ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៨ A189/I/5 វាក្យខណ្ឌទី៣។

[៣] វិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (វិសោធនកម្មលើកទី១) ចុះថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០០៨។

[៤] សេចក្ដីណែនាំអនុវត្ត អ.វ.ត.ក/០១/២០០៧/វិសោធនកម្មលើកទី២។

អង្គបុរេជំនុំជម្រះ
PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE
E.C.C.C. C.E.T.C.

## ហេតុដូច្នេះអង្គបុរេជំនុំជម្រះសម្រេច និងណែនាំ:

(១) បណ្តឹងឧទ្ធរណ៍នឹងធ្វើការសម្រេច ដោយផ្អែកលើសេចក្តីសន្និដ្ឋានតបរបស់ភាគីតែប៉ុណ្ណោះ។

(២) អនុញ្ញាតឱ្យជនត្រូវចោទដាក់សេចក្តីសន្និដ្ឋានតបទៅនឹងសេចក្តីសន្និដ្ឋានតបរបស់សហព្រះរាជអាជ្ញាក្នុងរយៈពេលប្រាំ(៥)ថ្ងៃ គិតចាប់ពីថ្ងៃជូនដំណឹងអំពីសេចក្តីសម្រេចនេះ។

ភ្នំពេញ ថ្ងៃទី៧ ខែសីហា ឆ្នាំ២០០៨

**ប្រធានអង្គបុរេជំនុំជម្រះ**

**ប្រាក់ គឹមសាន**